ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧១ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការអភិវឌ្ឍន៍គំរោង រៀបចំការផ្គត់ផ្គង់អគ្គិសនីជនបទ និង សាងសង់ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនីភាគខាងត្បូង

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៤៨ សសរ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមការងារសំរាប់រៀបចំគោលនយោបាយថាមពល និង ឧស្ម័នជាតិ
- យោងតាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើត ការអភិវឌ្ឍន៍គំរោងរៀបចំការផ្គត់ផ្គង់អគ្គិសនីជនបទ និង សាងសង់ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនីភាគខាងត្បូង ភ្ជាប់ពីព្រំប្រទល់វៀតណាមមកភ្នំពេញ ដែលរៀបចំដោយធនាគារពិភពលោក ។ គំរោងទាំងពីរនេះត្រូវបានកំណត់ថាជាគំរោងដែលមានអាទិភាពខ្ពស់ ។

**ប្រការ ២ :** គំរោង " សាងសង់ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនីភាគខាងត្បូង " ដែលភ្ជាប់ពីព្រំប្រទល់នៃប្រទេសវៀតណាមមកទីក្រុងភ្នំពេញ ត្រូវសាងសង់អោយរួចស្រេចនៅឆ្នាំ ២០០៣ ស្របតាមយុទ្ធសាស្ត្រផែនការវិស័យអគ្គិសនី ។

www.pheakdeylaw.com

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គិសនីកម្ពុជា និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com